សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា
CAMBODIAN UNIVERSITY FOR SPECIALTIES
Education for an Excellent Career

# ព្រឹត្តិបត្រព័ត៌មាន

## ត្រីមាសទី១ ឆ្នាំ ២០២៣

(ខែ មករា ដល់ខែមីនា)

*គុណភាពសិក្សា*

*សមត្ថភាពវិជ្ជាជីវៈ*

*បុគ្គលិកលក្ខណសម្បត្តិល្អប្រពៃ*

*សិក្សានៅ CUS!*

សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា
CAMBODIAN UNIVERSITY FOR SPECIALTIES
Education for an Excellent Career

# ព្រឹត្តិបត្រព័ត៌មាន



## សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា

## លើកកម្ពស់គុណភាពអប់រំដើម្បីគុណប្រយោជន៍សង្គមជាតិ

**គុណភាពអប់រំ គឺជាការលើកកម្ពស់គុណភាពបង្រៀន រៀន ស្រាវជ្រាវ និងសេវាកម្ម ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសន្សំសំចៃ**

ត្រីមាសទី១ ឆ្នាំ ២០២២

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| | **សកម្មភាពសិក្សា និងស្រាវជ្រាវ** | |
| ១. | ប្រតិភូសាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យឯកទេសនៃកម្ពុជាទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅក្នុងដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពី តួនាទី និងភារកិច្ចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី | ១ |
| ២. | សាកលវិទ្យាល័យ CUS រៀបចំសន្និសីទក្រោមប្រធានបទ ការសិក្សានៅឧត្តមសិក្សាក្នុងអំឡុងពេលកូវីដ១៩ គឺជាឱកាសនៅខេត្តកំពង់ធំ និងកំពង់ចាម | ២ |
| ៣. | សាកលវិទ្យាល័យឯកទេសនៃកម្ពុជា រៀបចំកម្មវិធីបទបង្ហាញច្បាប់អនឡាញ ដើម្បីចែករំលែកចំណេះដឹងផ្នែកច្បាប់ជូនដល់សាស្ត្រាចារ្យ និស្សិត និងសាធារណជន | ៤ |
| ៤. | សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា យកចិត្តទុកដាក់ខ្ពស់ក្នុងការបណ្តុះបណ្តាលកម្មសិក្សាការីផ្នែកច្បាប់ | ៥ |
| | **សកម្មភាពសង្គម** | |
| ៥. | គណៈគ្រប់គ្រង និងសាស្ត្រាចារ្យសាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខាកំពត ដឹកនាំនិស្សិតដាំដើមកោងកាង ក្នុងតំបន់សហគមន៍ ការពារអភិរក្សធនធានធម្មជាតិ | ៧ |
| | **ដំណឹងអាហារូបករណ៍ និងវគ្គសិក្សាច្បាប់** | |
| ៦. | ឱកាសទទួលបានអាហារូបករណ៍សិក្សានៅសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា | ៨ |
| ៧. | វគ្គសិក្សាខ្លី៖ ជំនួយការផ្នែកច្បាប់ ( Legal Assistant ) | ៩ |
| ៨. | វគ្គសិក្សាខ្លី៖ វាក្យសព្ទច្បាប់ជាភាសាអង់គ្លេស ( Legal Terminology ) | ១០ |

# ពិធីប្រគល់សញ្ញាបត្រជូននិស្សិតជ័យលាភី សាខាសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា,CUS ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ




**បាត់ដំបង÷**

នៅថ្ងៃទី០១ខែមិនាឆ្នាំ២០២៣ នៅខេត្តបាត់ដំបង សាកលវិទ្យាល័យឯកទេស នៃ កម្ពុជា CUS ឯកឧត្តមបណ្ឌិត **ស្តើង សុខុម** ប្រធានក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជាបាន សម្តែងគារវកិច្ចគោរពស្វាគមន៍ដ៏ខ្ពង់ខ្ពស់ និង ធ្វើសេចក្តីរាយការណ៍ជូនចំពោះសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ព្រមទាំងនិស្សិតទាំងអស់ ក្នុងពិធីប្រគល់សញ្ញាបត្រនិស្សិតជ័យលាភីនៃ សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា សាខាខេត្តបាត់ដំបង និង សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា សាខាខេត្តបន្ទាយមានជ័យចំនួន ១,៥៥០ នាក់ (នារី ៧៤០ នាក់ ស្មើនិង ៤៧,៨៧ ភាគរយ) ដែលអ្នកទទួលបានជោគជ័យក្នុងការសិក្សារបស់ខ្លួននាឆ្នាំកន្លងមក។







# តំណាងសាកលវិទ្យាល័យឯកទេសនៃកម្ពុជាចូលរួមជាគណកម្មការពិនិត្យនិង សង្កេតការណ៍ពេលប្រឡងមន្ត្រី និងសិស្ស-និស្សិត ចូលសិក្សានៅសាលាភូមិន្ទរដ្ឋបាល

**ភ្នំពេញ៖** ឯកឧត្តមបណ្ឌិត **កែវ ជា** សាកលវិទ្យាធិការរង សាកលវិទ្យាល័យឯកទេសនៃកម្ពុជាបានចូលរួមជាអ្នកពិនិត្យនិងសង្កេតការណ៍ពេលប្រឡងមន្ត្រីរាជការ និងសិស្ស-និស្សិត ចូលសិក្សានៅសាលាភូមិន្ទរដ្ឋបាល នៅថ្ងៃទី១៨ខែធ្នូឆ្នាំ២០២២ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ព្រំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងអមដំណើរដោយឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈនិងជានាយកសាលាភូមិរដ្ឋបាលដែលមានចូលរួមពីសំណាក់គណៈគ្រប់គ្រងនៃសាកលវិទ្យាល័យ និង វិទ្យាស្ថានរដ្ឋនិងឯកជនចំនួន ១៥ ទៀត ដូចជា សាកលវិទ្យាល័យនិតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យជាតិសុខាភិបាល សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យការពារជាតិ សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា វិទ្យាស្ថានសេដ្ឋកិច្ច-ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ល។








# ពិធីប្រគល់សញ្ញាបត្រជូននិស្សិតជ័យលាភី សាខាសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា,CUS ខេត្តសៀមរាប ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ស៊ាន បូរាត រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

(សៀមរាប)៖ នៅព្រឹកថ្ងៃអង្គារ ទី០៤ ខែកក្កដា ឆ្នាំ២០២៣កន្លងទៅនេះឯកឧត្តមបណ្ឌិត **ស៊ាន បូរាត** រដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡាតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យឯកទេសនៃកម្ពុជាសាខាខេត្តសៀមរាប(CUS)ចំនួន ២,១៤១នាក់ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ។ ពិធីនេះប្រារព្ធឡើង នៅសាលសន្និសីទធំសណ្ឋាគារសុខាសៀមរាប។ តាមរបាយការណ៍បានឱ្យដឹងថា សាកលវិទ្យាល័យ បានប្រារព្ធពិធីប្រគល់សញ្ញាបត្រចំនួន០៩លើករួចមកហើយ។ ចំនួន០៨លើក ធ្វើនៅរាជធានីភ្នំពេញក្រោមអធិបតីដ៏ខ្ពង់ខ្ពស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងមួយលើកក្រោមអធិបតីសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ដែលប្រារព្ធធ្វើឡើងនៅខេត្តបាត់ដំបង។ចំណែកពិធីប្រគល់សញ្ញាបត្រលើកទី១០ ប្រារព្ធធ្វើឡើងក្រោមអធិបតី ឯកឧត្តមបណ្ឌិត ស៊ាន បូរាត តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា។ឯកឧត្តមបណ្ឌិត**មាស ប៉ូរ៉ា** សាកលវិទ្យាធិការ បានបង្ហាញក្តីសោមនស្សរីករាយក្រៃលែង ដែលក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ និងនិស្សិតជ័យលាភីទាំងអស់ នៃសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជាសាខាខេត្តសៀមរាបមានពិធីកិត្តិយសនេះ។










# ពិធីប្រគល់ពិធីប្រគល់-ទទួលសៀវភៅ ចំនួន២១៩ក្បាល ពីឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




**ភ្នំពេញ៖** ថ្ងៃសុក្រ ១៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័កព.ស.២៥៦៧ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០២៣ ឯកឧត្តមបណ្ឌិត **កែវ ជា**សាកលវិទ្យាធិ - ការរង តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **មាសប៉ូវ៉ា** សាកលវិទ្យាធិការសាកលវិទ្យាល័យឯកទេសនៃកម្ពុជានិងគណៈគ្រប់គ្រងសាកលវិទ្យាល័យឯកទេសនៃកម្ពុជាបានអញ្ជើញចូលរួមក្នុងកម្មពិធីប្រគល់-ទទួលអំណោយជាសៀវភៅកម្រងបទបញ្ញត្តិគតិយុត្ត ចំនួន២១៩ក្បាល ពីឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Donation of books (219 Books (17 Sets) from the Ministry of Economy and Finance)។ ក្នុងនោះ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការរងបានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងសូមអរគុណចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** រដ្ឋលេខាធិការ និងឯកឧត្តម លោកជំទាវ អស់លោកលោកស្រី សហការីអមដំណើរ និងគណៈអធិបតី ភ្ញៀវកិត្តិយសនិងប្អូនៗក្មួយៗនិស្សិតទាំងអស់ដែលបានអញ្ជើញចូលរួមស្តីពីការប្រគល់-ទទួលអំណោយជាសៀវភៅអាននេះ។ ឯកឧត្តមតំណាង និងគណៈគ្រប់គ្រងសាកលវិទ្យា-ល័យ មានមោទកភាពក្រៃលែងចំពោះការរៀបចំពិធីប្រគល់-ទទួលអំណោយជាសៀវភៅនេះ។









# ពិធីពិព័រណ៍វិជ្ជាជីវៈអប់រំអាស៊ាន-ចិន ឆ្នាំ២០២៣ នៅទីក្រុងណានីង ក្វាងស៊ី ប្រទេសចិន

[China-ASEAN Vocational Education Exhibition and Forum 2023 Nanning, Guangxi, China]




ក្រុងណានីង ក្វាងស៊ី ប្រទេសចិន ៖ ថ្ងៃសុក្រ ១៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័កព.ស.២៥៦៧ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ លោក **ឌៃ សំអាត** សាកលវិទ្យាធិការរងប្រចាំការតំណាង ឯកឧត្តមបណ្ឌិត **មាស ម៉ូរ៉ា** សាកលវិទ្យាធិការសាកលវិទ្យាល័យឯកទេសនៃកម្ពុជា បានដឹកនាំសមាជិកគណៈប្រតិភូមួយក្រុមចំនួន០៤រូបដែលជាគណៈគ្រប់គ្រងសាកលវិទ្យាល័យឯកទេសនៃកម្ពុជារួមជាតំណាងរាជបណ្ឌិតសភាកម្ពុជា០១រូបផងដែរដើម្បីទៅចូលរួមក្នុងកម្មពិធីពិព័រណ៍វិជ្ជាជីវៈអប់រំអាស៊ាន-ចិនឆ្នាំ២០២៣ នៅទីក្រុងណានីង ក្វាងស៊ី ប្រទេសចិន [China-ASEAN Vocational Education Exhibition and Forum 2023 Nanning, Guangxi, China] ដើម្បីស្វែងយល់ និងដកពិសោធការងារជាមួយដៃគូភាគីចិន ។












(បន្តពីទំព័រ២)

សន្និសីទស្តីពី មាគ៌ាឆ្ពោះទៅកាន់ភាពជោគជ័យ និងឧត្តមានុភាព សាខាសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តបាត់ដំបង




លោក **តាក តាក់នីតា** នាយកសាខាខេត្តកំពង់ធំ និងលោក **ហែម បញ្ញា** នាយកសាខាខេត្តកំពង់ចាម បានបង្ហាញថា CUS បានដំណើរការជាង២០ឆ្នាំហើយទទួលបានជោគជ័យជាច្រើន មាននិស្សិតកំពុងសិក្សា ជិត២០,០០០នាក់ និងនិស្សិតបានបញ្ចប់ការសិក្សាជាង ៤០,០០០នាក់ នៅទូទាំងប្រទេស ដែលរួមមាន២ទីតាំង នៅរាជធានីភ្នំពេញ និង ខេត្តចំនួន ៦ មានខេត្តកំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង និងខេត្តកំពត។



បណ្ឌិត **សឿ យ៉ាន** សាកលវិទ្យាធិការរង បានលើកឡើង នូវមូលដ្ឋានជ្រើសរើសជំនាញ និងការសិក្សាស្រាវជ្រាវ ដូចម្តេចដើម្បីឲ្យទទួលបានជោគជ័យ ទទួលបានការងារល្អក្រោយបញ្ចប់ការសិក្សា។



លោក **ជួន ដារ៉ារិទ្ធ** នាយកធនាគារព្រីនស៍ ខេត្តកំពង់ធំ,លោក **ខៀវ ឡឿន**ប្រធានមជ្ឈមណ្ឌលការងារប្រចាំខេត្តកំពង់ធំ លោក **សុខ សារ៉ែម**ប្រធានមជ្ឈមណ្ឌលការងារប្រចាំខេត្តកំពង់ចាម លោក **ចេក ម៉េងឆន់** មន្ត្រីជាន់ខ្ពស់ផ្នែកធនធានមនុស្ស ក្រុមហ៊ុនមេហ្គាលីស៊ីងភីអិលស៊ី បានចែករំលែកនូវព័ត៌មានទូទៅលើស្ថាប័នរៀងៗខ្លួន ព្រមទាំងអះអាងដូចៗគ្នា នូវជំនាញរឹង និងទំនាញទន់ បុគ្គលិកលក្ខណសម្បត្តិដែលបុគ្គលមានដើម្បីទទួលបានការងារពីស្ថាប័នរបស់លោក។



បណ្ឌិត **កែវ ដា** សាកលវិទ្យាធិការរង ក៏បានធ្វើបទបង្ហាញពី“**គន្លឹះជោគជ័យក្នុងការសិក្សានិងការអភិវឌ្ឍខ្លួន**” ដោយសង្កត់ធ្ងន់លើការតស៊ូព្រមទាំងបានប្រៀបធៀបអំពីវិធីសាស្រ្តសិក្សាជោគជ័យរបស់យុវជនប្រទេសជប៉ុនដែលចាប់ផ្តើមពីការសន្សំពេលវេលាឡើងទៅ។




នៅចុងបញ្ចប់បណ្ឌិត **មាស ប៉ូវ៉ា** ក្នុងនាមប្រធានដឹកនាំនៃអង្គសន្និសីទ បានបូកសរុបថា ដើម្បីការរីកចម្រើនឥតមានព្រំដែន បុគ្គលខ្លួនឯងជាអ្នកទទួលខុសត្រូវលើជោគវាសនាខ្លួនឯង ជាពិសេសក្នុងយុគសម័យ ព័ត៌មានវិទ្យា និងសេដ្ឋកិច្ច ចំណេះដឹងគឺចាំបាច់ណាស់ត្រូវអភិវឌ្ឍខ្លួន ហេតុនេះការបន្តការសិក្សាជាការងារសំខាន់អាទិភាពសម្រាប់ប្អូនៗដើម្បីទទួលបានដំណេះដឹងកាន់តែច្រើនពីកម្រិតមួយទៅកម្រិតមួយនាំឲ្យមានបញ្ញាគិតត្រឹមត្រូវ នាំឲ្យជីវិតមានភាពប្រសើរឡើង។ ការសម្រេចបានទាមទាឲ្យមានការតស៊ូព្យាយាមមិនបោះបង់ធ្វើការងារយ៉ាងសកម្មឲ្យបានច្រើន នេះជាទ្រឹស្តីទូទៅសម្រាប់ឲ្យបុគ្គលជោគជ័យ។





CUSត្រៀមខ្លួនជាស្រេចដើម្បីជួយនិងណែនាំប្អូនៗឲ្យដល់ត្រើយជោគជ័យ។ សាកលវិទ្យាល័យរៀបចំបទឧទ្ទេសនាមដោយសាស្រ្តាចារ្យល្បីៗ រៀបចំកម្មវិធីសន្និសីទដោយទៀងទាត់ដើម្បីផ្តល់ចំណេះដឹង ជំរុញការស្រាវជ្រាវ ផ្តល់វគ្គសិក្សាជំនាញខ្លីៗ ការចុះកម្មសិក្សា ទស្សនកិច្ចសិក្សា និងមានការចុះ MOU ជាមួយសាកលវិទ្យាល័យក្រៅស្រុកជាច្រើន៕



# សាកលវិទ្យាល័យឯកទេសនៃកម្ពុជា រៀបចំកម្មវិធីបទបង្ហាញច្បាប់អនឡាញ ដើម្បីចែករំលែកចំណេះដឹងផ្នែកច្បាប់ជូនដល់សាស្ត្រាចារ្យ និស្សិត និងសាធារណជន

**ភ្នំពេញ៖**




កម្មវិធីបទបង្ហាញច្បាប់អនឡាញ ត្រូវបានផ្តួចផ្តើមគំនិតដោយបណ្ឌិត **មាស បូរ៉ា** សាកលវិទ្យា-ធិការនៃសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា ក្នុងគោលបំណងចែករំលែកចំណេះដឹងផ្នែកច្បាប់ក្នុងរង្វង់អ្នកសិក្សាស្រាវជ្រាវ និស្សិត និងសាធារណជន។ កម្មវិធីនេះ បានធ្វើឡើងចំនួន៧លើកនៅឆមាសទី២ ឆ្នាំ២០២១។

ចំណែកនៅត្រីមាសទី១ ឆ្នាំ២០២២ នេះ យើងបានរៀបចំបទបង្ហាញចំនួនពីរលើកគឺ៖




(១) បទបង្ហាញក្រោមប្រធានបទ ***"ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម"*** នៅថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ២:០០ ដល់ម៉ោង ៤:៣០នាទី ដោយបណ្ឌិត **លឹម លីហុង** ជាវាគ្មិនកិត្តិយស។ ក្នុងបទបង្ហាញ ដែលមានអ្នកចូលរួមចំនួន ៤៥នាក់ លោក វាគ្មិនបានលើកឡើងអំពីដើមទំនើប ទ្រឹស្តីនានាទាក់ទងនឹងការជានាឯករាជ្យនៃអំណាចតុលាការ សារសំខាន់នៃឯករាជ្យអំណាចតុលាការ សញ្ញាណប្រវត្តិនៃក្រុមប្រឹក្សាចៅក្រម ការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា តាមបញ្ញត្តិរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់ខាងលើ។

(២) បទបង្ហាញក្រោមប្រធានបទ ***"កិច្ចស៊ើបសួរ"*** នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ២:០០ ដល់ម៉ោង ៤:៣០នាទី ដោយលោកចៅក្រម **ម៉ម ច័ន្ទវណ្ណៈ** ជាវាគ្មិនកិត្តិយស។ ក្នុងបទបង្ហាញដែលមានអ្នកចូលរួមចំនួន ៦៥នាក់ លោកវាគ្មិនបានបកស្រាយយ៉ាងក្បោះក្បាយអំពីខ្លឹមសារច្បាប់នីតិវិធីនិងដំណើរការនៃការស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ។

## សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា យកចិត្តទុកដាក់ខ្ពស់ក្នុងការបណ្តុះបណ្តាលកម្មសិក្សាការីផ្នែកច្បាប់

**ភ្នំពេញ៖**

ក្រោមការដឹកនាំរបស់បណ្ឌិត សាកលវិទ្យាធិការ **មាស ម៉ូរ៉ា** មជ្ឈមណ្ឌលបណ្តុះបណ្តាលដើម្បីការងារនិងការស្រាវជ្រាវនៃ សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា បានជ្រើសរើសនិស្សិតជាកម្មសិក្សាការី និង បណ្តុះបណ្តាលលើជំនាញស្រាវជ្រាវច្បាប់ដល់និស្សិតបានជាច្រើនរូប ប្រកបដោយសមត្ថភាពស្រាវជ្រាវ និងសមត្ថភាពវិជ្ជាជីវៈ។



នៅត្រីមាសទី១ ឆ្នាំ២០២២ នេះ មជ្ឈមណ្ឌលបានរៀបចំជាបទបង្ហាញកិច្ចការស្រាវជ្រាវ របស់កម្មសិក្សាការីចំនួន ៨ លើក ក្រោមប្រធានបទដូចជា៖ (១) បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ (២) បទល្មើសប្រល័យពូជសាសន៍ (៣) កាតព្វកិច្ចនៃការបង្ហាញភស្តុតាង (៤) យុត្តាធិការ៖ករណីសិក្សាលោកអាឌុលអេជមែន (Adolf Eichmann) (៥) អាជ្ញាអស់ជំនុំក្នុងរឿងព្រហ្មទណ្ឌ (៦) Hostage Taking (៧) Sexual Violence និង (៨) ច្បាប់ភូមិបាលឆ្នាំ២០០១។





គួរបញ្ជាក់ផងដែរថា បណ្ណាល័យស្រាវជ្រាវនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលដើម្បីការងារនិងការស្រាវជ្រាវ មានសៀវភៅសិក្សាច្បាប់សម្បូរបែប និងទទួលស្វាគមន៍និស្សិតគ្រប់រូបចូលស្រាវជ្រាវ។ មិនតែប៉ុណ្ណោះ មជ្ឈមណ្ឌល មានទទួលកម្មសិក្សាការីផ្នែកច្បាប់ថ្មីជារៀងរាល់៣ខែម្តង។ សូមទំនាក់ទំនងមជ្ឈមណ្ឌល នៅសាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខាស្ទឹងមានជ័យ នៅជាន់ទី១ សម្រាប់ព័ត៌មានកម្មសិក្សា៕

## គណៈគ្រប់គ្រង និងសាស្ត្រាចារ្យសាកលវិទ្យាល័យឯកទេសនៃកម្ពុជា សាខាកំពត ដឹកនាំនិស្សិតដាំដើមកោងកាង ក្នុងតំបន់សហគមន៍ ការពារអភិរក្សធនធានធម្មជាតិ

***កំពត៖***

នៅព្រឹកថ្ងៃអង្គារ៦កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមនាយក ហម សាវេត គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ និងនិស្សិត នៃសាខាសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តកំពត(CUS.KP) សរុបចំនួន ៥០ នាក់ បានដាំដើមកោងកាងចំនួន ១៦៨ ដើម នៅក្នុងសហគមន៍នេសាទត្រពាំងសង្កែ ដែលស្ថិតនៅក្នុងភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។

ឯកឧត្តមនាយក ហម សាវេត បានឱ្យដឹងថា៖ "គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ និងនិស្សិត បានចូលរួមដាំដើមកោងកាងនេះ គឺក្នុងគោលបំណង ជួយបង្កើនគម្របព្រៃកោងកាង អភិរក្ស ជីវចម្រុះផ្សេងៗ ក៏ដូចជាការរក្សាអេកូទេសចរណ៍ក្នុងតំបន់សហគមន៍ ការពារអភិរក្សធនធានធម្មជាតិ ព្រមទាំងជម្រុញឱ្យមានការដាំកូនដើមកោងកាងបន្ថែមទៀតផងដែរ។" ឯកឧត្តមនាយក ក៏បានបន្ថែមទៀតផងដែរថា៖ ***"ដើមកោងកាង គឺជាផ្ទះ ជាជម្រករបស់ជីវចម្រុះផ្សេងៗ"។***









# ឱកាសទទួលបានអាហារូបករណ៍សិក្សានៅសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា







សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា លើកកម្ពស់ ការសិក្សាស្រាវជ្រាវក្រោមពាក្យស្លោក "*សិក្សាដើម្បីគុណភាព សិក្សាដើម្បីសមត្ថភាពវិជ្ជាជីវៈ បុគ្គលិកលក្ខណសម្បត្តិល្អប្រពៃ*"។

ដើម្បីជួយសម្រួលដល់ជីវភាពនិស្សិត និងអាណាព្យាបាល សាកលវិទ្យាល័យនឹងផ្តល់អាហារូបករណ៍ជាច្រើនកន្លែង ដល់និស្សិតលើគ្រប់ជំនាញសិក្សា និងនៅគ្រប់កម្រិតសិក្សា! សូមនិស្សិត និងអាណាព្យាបាល រួសរាន់ទំនាក់ទំនងដាក់ពាក្យសុំអារូបករណ៍ តាមព័ត៌មានដែលបានផ្តល់ជូនដូចខាងក្រោម៖

☛ *ទីតាំង/សាខា និងកម្រិតសិក្សារបស់សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា (CUS)*

១. CUS ទួលគោក៖ 012 63 62 07 / 087 63 62 07

២. CUS ស្ទឹងមានជ័យ៖ 070 70 88 83 / 089 80 88 85

៣. CUS កំពង់ចាម៖ 012 44 27 27 / 015 44 27 27

៤. CUS កំពង់ធំ៖ 012 85 43 42 / 087 85 43 42

៥. CUS សៀមរាប៖ 012 63 62 08 / 010 63 62 08

៦. CUS បន្ទាយមានជ័យ៖ 012 29 11 40 / 081 29 11 40

៧. CUS បាត់ដំបង ៖ 012 44 27 28 / 093 44 27 28

៨. CUS កំពត ៖ 012 76 92 20 / 069 55 58 11

☛ *ទំនាក់ទំនងចុះឈ្មោះចូលរៀនតាមរយៈលេខ៖ 012 63 62 08/ 070 70 88 83*

## វគ្គសិក្សាខ្លី៖ ជំនួយការផ្នែកច្បាប់

( Legal Assistant )




សូមជម្រាបជូនដំណឹងដល់ លោក លោកស្រី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវច្បាប់ និស្សិត និងអតីតនិស្សិតច្បាប់ទាំងអស់អោយបានជ្រាបថា សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជាCUS (ទីតាំងស្ទឹងមានជ័យ) នឹងបើកវគ្គសិក្សាខ្លីស្តីពីជំនួយការផ្នែកច្បាប់ (Legal Assistant)។ វគ្គសិក្សានេះ នឹងផ្តល់ចំណេះដឹងទាក់ទងនឹងការរៀបចំបណ្តឹង និងនីតិវិធីតុលាការ ការព្រាងកិច្ចសន្យា កិច្ចការងាររដ្ឋបាល ការរៀបចំ និងសរសេរសារណាច្បាប់ ទំនាក់ទំនងព័ត៌មានការងារ ការសរសេរ CV និងការសម្ភាសន៍ការងារ /កុំព្យូទ័រ សម្រាប់ការស្រាវជ្រាវ។ នៅពេលចប់វគ្គសិក្សានេះសិក្ខាកាមនឹងមានសមត្ថភាពក្លាយជាជំនួយការផ្នែកច្បាប់ ដូចជា ជំនួយការមេធាវី....។ល។ វគ្គសិក្សានេះចូលរៀននៅថ្ងៃសៅរ៍ ទី៣០ ខែមេសា ឆ្នាំ២០២២ ឆាប់ៗខាងមុខនេះ!

- ☛ សិក្សារៀងរាល់ថ្ងៃ សៅរ៍ ម៉ោង ៨៖០០ព្រឹក ដល់ម៉ោង ១១៖៣០ព្រឹក!!
- ☛ តំលៃសិក្សា៧០ដុល្លារ (អាចបង់ជាពីរដំណាក់កាល)!!
- ☛ សូមចុះឈ្មោះចូលរៀន តាម Link ខាងក្រោម៖

https://forms.gle/rfsFp7ZdQN6LuP7DA

# វគ្គសិក្សាខ្លីៈ វាក្យសព្ទច្បាប់ជាភាសាអង់គ្លេស

( Legal Terminology )




សូមជម្រាបជូនដំណឹងដល់លោកគ្រូ អ្នកគ្រូ និស្សិត និងអតីតនិស្សិតច្បាប់ទាំងអស់ អោយបានជ្រាបថា សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា (CUS) នឹងបើវគ្គសិក្សាខ្លីស្តីពីវាក្យសព្ទច្បាប់ជាភាសាអង់គ្លេស (Legal Terminology)។

វគ្គសិក្សានេះ នឹងជួយបង្កើនចំណេះដឹងភាសាអង់គ្លេសច្បាប់ ដល់និស្សិតច្បាប់! វគ្គសិក្សានេះចូលរៀននៅថ្ងៃសៅរ៍ ទី២៣ ខែមេសា ឆ្នាំ ២០២២ ឆាប់ៗខាងមុខនេះ! សិក្សារៀងរាល់ថ្ងៃសៅរ៍ ម៉ោង៨:០០ព្រឹក ដល់ម៉ោង ១១:៣០ព្រឹក!!

- ☛ តំលៃសិក្សា ៥០ដុល្លារ!!
- ☛ សូមចុះឈ្មោះចូលរៀន តាម Link ខាងក្រោមៈ

https://forms.gle/roL7zLyotdCpKyK89

# គុណភាព សមត្ថភាពវិជ្ជាជីវៈ បុគ្គលិកលក្ខណសម្បត្តិល្អ










## សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា

CAMBODIAN UNIVERSITY FOR SPECIALTIES

EDUCATION FOR AN EXELENT CAREER

### អាស័យដ្ឋាន(ភ្នំពេញ)÷

- **CUS ទួលគោក៖** កៀ្បរអង់តែនទូរទស្សន៍ជាតិទួលគោក
  ទូរស័ព្ទ៖ ០២៣ ៣៥ ០៨ ២៨ / ០១២ ៦៣ ៦២ ០៧
- **CUS ស្ទឹងមានជ័យ៖** ៣០០ម៉ែត្រពីគល់ស្ពានស្ទឹងមានជ័យ
  ទូរស័ព្ទ៖ ០៨៩ ៨០ ៨៨ ៨៥ / ០១២ ៦៣ ៦២ ០៧

### អាស័យដ្ឋាន(ខេត្ត)÷

- **CUS កំពង់ចាម៖** ផ្លូវព្រះមុនីវង្ស ភូមិជ្រោយថ្ម ក្រុងកំពង់ចាម
  ទូរស័ព្ទ ៖ ០១២ ៤៤ ២៧ ២៧ / ០១៦ ៩៨ ៧៦ ៣០
- **CUS កំពង់ធំ៖** ភូមិបល្ល័ង្គខាងលិច ក្រុងកំពង់ធំ
  ទូរស័ព្ទ៖ ០១២ ៤៤ ២៧ ២៧ / ០១៦ ៩៨ ៧៦ ៣០
- **CUS សៀមរាប៖** ផ្លូវតាណឺយ ក្រុងសៀមរាប
  ទូរស័ព្ទ៖ ០១២ ៦២ ៦៣ ០៨ / ០៨០ ៦២ ៦៣ ០៨
- **CUS បន្ទាយមានជ័យ៖** ភូមិក្នុំកន្ទួរ ក្រុងសិរីសោភ័ណ្ឌ (ជិតផ្សារបំការគរ) ទូរស័ព្ទ ០១២ ២៩ ១១ ៤០ / ០៩៣ ២៩ ១១ ៤០
- **CUS បាត់ដំបង៖** ភូមិអូរតាគាំ២ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ទូរស័ព្ទ៖ ០១២ ៤៤ ២៧ ២៨ / ០៩៣ ៤៤ ២៧ ២៨
- **CUS កំពត៖** អគារ២១ ទល់មុខរង្វង់មូល២០០០ ទីរួមខេត្តកំពត ទូរស័ព្ទ៖ ០១២ ៧៦ ៩២ ២០ / ០៦៩ ៥៥ ៥៨ ១១

Email: info@cus.edu.kh

Website: http://www.cus.edu.kh